ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៩៤/១៤- ស៊ិចផ្លាស អ៊ិនដាសស្រ្ទី ខូ អិលធីឌី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គឹមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ស៊ិចផ្លាស អ៊ិនដាសស្ទ្រី ខូ អិលធីឌី**

អាសយដ្ឋាន ៖ ភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៨៨ ៦០០ ០០០៣ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

- លោក គង់ ផានិត រដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **តំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ស៊ិចផ្លាស អ៊ិនដាសស្ទ្រី ខូ អិលធីឌី**

អាសយដ្ឋាន ៖ ភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល

ទូរស័ព្ទ ៖ គ្មាន ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖ គ្មាន



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ទាមទារឱ្យរដ្ឋាភិបាល និងនិយោជកដោះលែងជនជាប់ចោទទាំង ២១ នាក់។

២- ស្នើឱ្យក្រុមហ៊ុនមានការចរចាប្រាក់ឈ្នួលគោល ១៦០ ដុល្លារ ក្នុងមួយខែ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៤៥៧/១៤ ក.ប/ក.ណ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤។

## សវនាការ និង សង្ខេបនីតិវិធី

### បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានដំណើរការផ្សះផ្សាវិវាទការងាររួមចំនួន ០២ ចំណុច ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាទេ ព្រោះថាភាគីកម្មករនិយោជិតអវត្តមានដោយគ្មានដំណឹង។

ចំណុចមិនសះជាចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពីការផ្សះផ្សាវិវាទការងាររួមលេខ ៤៥៧/១៤ កប/កណ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០១៤។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង ០៨៖៣០ នាទីព្រឹក។ ភាគីនិយោជកបានទទួលការអញ្ជើញ និងបានមកចូលរួមសវនាការ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ចំណែកឯភាគីកម្មករនិយោជិតវិញ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានយកលិខិតអញ្ជើញទៅជូនកម្មករនិយោជិតដល់រោងចក្រ ប៉ុន្តែ មិនមានកម្មករនិយោជិត

ណាម្នាក់ទទួល អះអាងថា ខ្លួនជាភាគីកម្មករនិយោជិតនៅក្នុងសំណុំរឿងនេះ និងទទួលយកលិខិតអញ្ជើញនេះឡើយ។ នៅថ្ងៃសវនាការ មិនមានតំណាងភាគីកម្មករនិយោជិតមកចូលរួមទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ស៊ិចផ្លាស អ៊ិនដាសស្ទ្រី ខូ អិលធីឌី ផ្ទេរសិទ្ធិជូនលោក គង់ ផានិត ជារដ្ឋបាល ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស៊ិចផ្លាស អ៊ិនដាសស្ទ្រី ខូ អិលធីឌី លេខ ៤៥៧/១៤ ក.ប/ក.ណ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ស៊ិចផ្លាស អ៊ិនដាសស្ទ្រី ខូ អិលធីឌី ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញតំណាងកម្មករនិយោជិតមកជ្រើសរើសអាជ្ញាកណ្តាល លេខ ៤៥៩ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្មើដោយសហជីព កម្មករនិយោជិត ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤។

៣- លិខិតអញ្ជើញភាគីតំណាងកម្មករនិយោជិតចូលរួមសវនាការ លេខ ៤៧០ កប/អក/វក/លកអ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៤៦៩ កប/អក/វក/លកអ ចុះថ្ងៃ ទី២៨ ខែមេសា ឆ្នាំ២០១៤។

**អង្គហេតុ ÷**

- លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញលិខិតអញ្ជើញលេខ ៤៧០ កប/អក/វក/លកអ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ ទៅ "លោក-លោកស្រី និងអ្នកតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ស៊ិចផ្លាស អ៊ិនដាស់ស្ទ្រី ខូអិលធីឌី" (ភាគីដើមបណ្តឹង) ដើម្បីមកចូលរួមសវនាការអាជ្ញាកណ្តាល នៃសំណុំរឿងលេខ ៩៤/១៤ - ស៊ិចផ្លាស អ៊ិនដាសស្ទ្រី ខូ អិលធីឌី ដែលមានព័ត៌មានដូចតទៅ ៖

- ○ កាលបរិច្ឆេទនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង ០៨ និង ៣០ នាទី និង
  ○ ទីកន្លែងនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២, ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ និង
  ○ ទូរស័ព្ទ/ទូរសារលេខ ០២៣ ៨៨១ ៨២៤។
- នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ ដដែលនេះ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានយកលិខិតអញ្ជើញទៅជូនកម្មករនិយោជិតដល់រោងចក្រ ប៉ុន្តែមិនមានកម្មករនិយោជិតណាម្នាក់ទទួលអះអាងថាខ្លួនជាភាគីកម្មករនិយោជិតនៅក្នុងសំណុំរឿងនេះ និងទទួលយកលិខិតអញ្ជើញនេះឡើយ។ កម្មករនិយោជិតដែលនៅរោងចក្របានបញ្ជាក់ថា គ្មានកម្មករនិយោជិតណាទាមទារលើចំណុចវិវាទទាំង ០២ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។
- នៅថ្ងៃសវនាការ មិនមានតំណាងភាគីកម្មករនិយោជិតមកចូលរួមទេ។
- ដោយមិនមានកម្មករនិយោជិតណាម្នាក់ទទួលអះអាងថា ខ្លួនជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ និងមិនមានវត្តមានរបស់ភាគីដើមបណ្តឹងធ្វើការទាមទារនៅក្នុងបណ្តឹងនេះមកចូលរួមសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការអាជ្ញាកណ្តាលនៃសំណុំរឿង ៩៨/១៤ - ស៊ិចផ្លាស អ៊ិនដាសស្ត្រី ខូអិលធីឌី ទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកអង្គហេតុទាក់ទងទៅនឹងចំណុចវិវាទ ដែលមានចែងនៅក្នុងរបាយការណ៍ស្តីពីការផ្សះផ្សាវិវាទការងាររួមលេខ ៤៥៧/១៤ កប/កណ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ ដែលមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលបានឡើយ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

**នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងត្រូវចាត់នីតិវិធីបែបណា ក្នុងករណីមិនមានដើមបណ្តឹង?**

ប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖*"ក្រុមអាជ្ញាកណ្តាល ត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និង ព័ត៌មានចាំបាច់ផ្សេងៗទៀត"*។

យោងតាមប្រការ ១៨ នៃប្រកាសលេខ ០៩៩/០៤ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កាតព្វកិច្ចរបស់ភាគីដើមបណ្តឹង និងភាគីចុងចម្លើយនៃសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺត្រូវមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន ក៏ដូចជាផ្តល់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗដែលពាក់ព័ន្ធនឹងចំណុចវិវាទ សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចសេចក្តី។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងទាមទាររបស់ខ្លួន។ ចំណែកឯភាគីចុងចម្លើយមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះបន្ទុករបស់ខ្លួនពីការទាមទារ ឬការចោទប្រកាន់ពីសំណាក់ដើមបណ្តឹង ដែលកាតព្វកិច្ចនេះ ជាទូទៅ នឹងត្រូវកើតឡើងក្រោយពេលដែលដើមបណ្តឹងបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាមុនសិន។

ក្នុងសំណុំរឿងនេះ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានយកលិខិតអញ្ជើញទៅជូនកម្មករនិយោជិតដល់រោងចក្រ ប៉ុន្តែ មិនមានកម្មករនិយោជិតណាម្នាក់ទទួលអះអាងថា ខ្លួនជាភាគីកម្មករ និយោជិត (ដើមបណ្តឹង) នៅក្នុងសំណុំរឿងនេះ និងទទួលយកលិខិតអញ្ជើញនេះឡើយ។ កម្មករនិយោជិតដែលនៅរោងចក្របានបញ្ជាក់ថា គ្មានកម្មករនិយោជិតណាទាមទារលើចំណុចវិវាទទាំង ០២ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មិនមានដើមបណ្តឹងទាមទារនៅក្នុងសំណុំរឿងនេះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ០៩៤/១៤ - ស៊ិចផ្លាស អ៊ិនដាសស្ត្រី ខូ អិលធីឌី។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

**សម្រេច និង បង្គាប់**

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ៩៤/១៤ - ស៊ិចផ្លាស អ៊ិនដាសស្ត្រី ខូ អិលធីឌី។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក**

ឈ្មោះ៖ **ម៉ារ សំបូរណា**

ហត្ថលេខា៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

ឈ្មោះ៖ **ស៊ីន គឹមស៊ាន**

ហត្ថលេខា៖ ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល**

ឈ្មោះ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា៖ ------------------------------

THE ARBITRATION COUNCIL